# “ការបូមបេតុង”

## ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

# បម្រុងប្រយ័ត្នចំពោះប្រតិបត្តិការបូមបេតុង

## (1) ការបូមបេតុងនៅក្រោមសម្ពាធខ្ពស់

ការបូមបេតុងគឺជាការងារមួយគ្រោះថ្នាក់ដែលបេតុងថ្មីត្រូវបញ្ជូនដោយសម្ពាធខ្ពស់។ ចូរចងចាំថាសម្ពាធបូមកាន់តែខ្ពស់ គ្រោះថ្នាក់ដែលអាចកើតឡើងក៏កាន់តែធំដែរ។



រថយន្តបូមបេតុងដែលបូមបេតុងលាយស្រេចដោយប្រើសម្ពាធខ្ពស់

## (2) ហាមផ្ដល់សញ្ញានាំផ្លូវដល់រថយន្តដឹកជញ្ជូនបេតុង

ហាមផ្ដល់សញ្ញានាំផ្លូវដល់រថយន្តដឹកជញ្ជូនបេតុង (ឡានក្រឡុកស៊ីម៉ងត៍) ឬចាត់ចែងទបង្ហូរ ពីព្រោះវាអាចបង្ករគ្រោះថ្នាក់ធ្ងន់ធ្ងរដូចជាការគាបជាប់
នៅចម្លោះរថយន្តក្រឡុកស៊ីម៉ងត៍និងរថយន្តបូមបេតុង។




ឧទាហរណ៍ពីគ្រោះថ្នាក់គាបជាប់នៅចន្លោះរថយន្តបូមបេតុង
និងរថយន្តក្រឡុកស៊ីម៉ងត៍ខណៈពេលកំពុងផ្ដល់សញ្ញានាំផ្លូវ

## (3) ហាមបំពេញការងារនៅលើអេក្រង់ជីឡៅ

ហាមបំពេញការងារនៅលើអេក្រង់ជីឡៅពីព្រោះជើងរបស់អ្នកអាចធ្លាក់ចូលក្នុងជីឡៅតាមប្រឡោះអេក្រង់ ហើយគាបជាប់ក្នុងធុងក្រឡុក ប្រសិនបើអ្នកបំពេញការងារនៅលើអេក្រង់ជីឡៅ។





ឧទាហរណ៍អំពីគ្រោះថ្នាក់ទាក់ទងនឹងជើងមនុស្សធ្លាក់ចូលតាមប្រឡោះអេក្រង់ជីឡៅ

## (4) ហាមប្រើប្រាស់សម្រាប់គោលបំណងផ្សេង

ការលើកបំពង់បញ្ជូននិងគ្រឿងបរិក្ខារដោយប្រើដងសន្ទូចអាចបណ្តាលឲ្យមានបន្ទុកនៅលើដងសន្ទូចដែលធ្វើឲ្យដងសន្ទូចបាក់។ មិនគួរប្រើដងសន្ទូចសម្រាប់អ្វីមួយផ្សេងក្រៅពីការប្រើប្រាស់ចម្បងរបស់រថយន្តបូមបេតុងឡើយ។



ហាមប្រើប្រាស់ដងសន្ទូចសម្រាប់គោលបំណងផ្សេង

## (5) ហាមបំពេញការងារនៅក្រោមដងសន្ទូច

### ហាមអនុញ្ញាតឲ្យបុគ្គលិកចូលក្រោមដងសន្ទូច។ អាចមានគ្រោះថ្នាក់ដល់បុគ្គលិកប្រសិនបើដងសន្ទូចនោះបាក់។



ហាមបំពេញការងារនៅក្រោមដងសន្ទូច



ឧទាហរណ៍អំពីគ្រោះថ្នាក់បាក់ដងសន្ទូច

# (6) ហាមបំពេញការងារនៅល្បឿនមួយដែលមិនសមស្រប

## ការបូមបេតុងក្នុងល្បឿនមិនសមស្របអាចបណ្ដាលឲ្យបែកធ្លាយបំពង់បញ្ជូន ឬអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ដូចជាការខ្ទាតបេតុងចំជាដើម។



ការបូមបេតុងដែលស៊ីគ្នានឹងល្បឿនចាក់និងការងារបង្ហាប់

## ( 7 ) បម្រុងប្រយ័ត្នចំពោះដងសន្ទូចអំឡុងពេលមានខ្យល់បក់ខ្លាំងនិងរន្ទះ

ហាមប្រើដងសន្ទូចនៅពេលល្បឿនខ្យល់មធ្យមលើសពី10 ម/វិ. ឬខ្ពស់ជាងនេះក្នុងរយៈពេល 10 នាទី, ឬនៅពេលល្បឿនខ្យល់ដែលកើតឡើងភ្លាមៗមានល្បឿន16 ម/វិ. ឬខ្ពស់ជាងនេះ។
ចូរបញ្ឈប់ប្រតិបត្តិការហើយទប់បង្រួមដងសន្ទូចដើម្បីបង្ការគ្រោះថ្នាក់នៅពេលមានហានិភ័យរន្ទះបាញ់។



បម្រាមចំពោះការប្រើដងសន្ទូចនៅពេលខ្យល់ខ្លាំង




បម្រាមចំពោះការប្រើដងសន្ទូចនៅពេលមានរន្ទះ

## (８) ផ្លាស់ទីរថយន្តបូមបន្ទាប់ពីបង្រួមដងសន្ទូចនិងជើងជ្រែង

នៅពេលផ្លាស់ទីរថយន្តនៅក្នុងការដ្ឋាន ចូរបង្រួមដងសន្ទូចនិងជើងជ្រែងឲ្យអស់ ហើយចាក់ខ្ចាស់ឧបករណ៍បង្ការដូចជាដែកខ្ចាស់ ឬប្រវាក់ឲ្យគត់មត់ មុននឹងផ្លាស់ទីរថយន្ត ដើម្បីចៀសវាងគ្រោះថ្នាក់ប៉ះទង្គិចនឹងវត្ថុបណ្ដោះអាសន្នឬខ្សែភ្លើងដែលនៅពីលើ។





ឧទាហរណ៍អំពីគ្រោះថ្នាក់ប៉ះទង្គិចដោយសារការបើកបររថយន្តដោយមិនបានបង្រួមដងសន្ទូច